៤១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨១៨
ចុះថ្ងៃទី០៩-៩-២០១១

សាលដីកា
លេខ: ២៥ ក្រ Vl ញ
ចុះថ្ងៃទី០៧-៣-២០១២

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើ តាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នា ថ្ងៃទី២៨-០២-២០១២ ដោយមានសមាសភាព ដូចតទៅ:

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងក្ដីព្រហ្មទណ្ឌលេខ:៨១៨ ចុះថ្ងៃទី០៩-៩-២០១១ រវាង:

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ អាយុ៥៨ឆ្នាំ កើតនៅភូមិកញ្ចំ ឃុំកញ្ចំ ស្រុកពារាំង ខេត្តព្រៃវែង សាសនាព្រះពុទ្ធ មុខរបរលក់ដូរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ: ៣៦E₆ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] ទោសពីមុនគ្មាន។

<u>ត្រូវចោទពីបទ:</u> **បង្ករបួសស្នាមដោយចេតនា និង ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅផ្សារសំពៅមាស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង តាមមាត្រា ៣០៧ និង មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។



Scanned by CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]ទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ: ១៦H សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

## ឯរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី១៩-៨-០៩ ម៉ោង ៥ និង៣០នាទីល្ងាច ពេលប្ដីឈ្មោ[redacted]បើកឡានចេញពីក្នុងផ្សារសំពៅមាស ពីកន្លែលក់ដូរខាងក្នុងមក តាមផ្លូវចំហៀងតូបរបស់ឈ្មោ[redacted]:មកដល់ចំនុចចំហៀងតូបស្រាប់តែឈ្មោះ [redacted]បានទំលាក់ទ្វារតូបមកប៉ះឡានរបស់ឈ្មោះ [redacted]តែពេលនោះដោយឈ្មោះ [redacted]នចុះត្រូវជូនកូនទៅសាលារៀនផង ក៏មិនបានចុះទៅសួរនាំអ្វីដែរ។ លុះព្រឹកថ្ងៃទី២០-៨-០៩ វេលាម៉ោង ៧ និង០០ នាទី ពេលប្ដីបើកឡានមកដល់ត្រង់ចំហៀងតូបរបស់ឈ្មោះ [redacted]ឈ្មោះ[redacted]ក៏ដើរទៅសួរនាំពីរឿងដែល[redacted]ធ្វើឲ្យប៉ះឡាន ពេលនោះស្រាប់តែឈ្មោ[redacted]បានជេរប្រមាថ និងចាប់មួលដៃឈ្មោ[redacted] បណ្ដាលឲ្យគ្រិចថ្លោះដៃយ៉ាងធ្ងន់ធ្ងរ ភ្លាមនោះប្ដីរបស់ [redacted]ឃើញដូចនោះក៏ចេញពីក្នុងឡានទៅចាប់ប្រពន្ធចេញតែម្ដង។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ: ០៩ "ន" ចុះថ្ងៃទី២១-០១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១.កែតម្រូវបទចោទប្រកាន់លើឈ្មោ[redacted]: ជេរប្រមាថ និង បរិហារកេរ្តិ៍ ប្រព្រឹត្តផ្សារសំពៅមាស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា កាលពីថ្ងៃទី២០-៨-២០០៩ តាមមាត្រា ៦៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មកបទជេរប្រមាថ ជាសាធារណៈ តាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ។

២.ផ្ដន្ទាទោសឈ្មោះ[redacted]ភេទប្រុស អាយុ៤៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ខែ តែទោសនេះត្រូវព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន ១ ០០០ ០០០ រៀល។

ពីបទ: បង្ករបួសស្នាមដោយចេតនា និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅផ្សារសំពៅមាស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០-៨-២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង តាមមាត្រា ៣០៧ និង មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

៣.បង្គាប់ឲ្យឈ្មោះ[redacted]ងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តចំនួន ៤ ០០០ ០០០រៀល ឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]ារទាមទារលើសពីនេះបដិសេធចោល។

៤.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។ បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**បានឃើញ** របាយការណ៍ ចុះថ្ងៃទី០២-១១-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

**បានឃើញ** សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី២៨-១១-២០១១ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។



Scanned by CamScanner

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]

(អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]

(វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា៖ រឿងហេតុកាលពីដំបូងឡើយ ខ្លួនបើកឡានកាត់មុខតូបរបស់ឈ្មោះ [redacted] ស្រាប់តែឈ្មោះ [redacted] កាត់បានធ្វើឲ្យដំបូលតូបរបស់គាត់មកប៉ះឡានរបស់ខ្លួន។ បន្ទាប់មកទៀតខ្លួនបានសួរនាំ ក៏កើតរឿងឈ្លោះប្រកែក និងជេរប្រមាថ មកលើខ្លួនយ៉ាងខ្លាំង។

នៅពេលនេះខ្លួនសំណូមពរសុំតម្កល់សាលក្រមរបស់សាលាដំបូងដដែល។

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន**

ការសម្រេចរបស់សាលាដំបូង សមល្មម និងអំពើប្រព្រឹត្ត របស់ជនជាប់ចោទ ហើយសុំសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូងក្រុងភ្នំពេញដដែល។

-ក្រោយពីស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់អំណានចម្លើយ របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១.បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-០១-២០១១ របស់ឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.តាមការប៉ះប៉ូររបស់ដើមបណ្តឹងថា កាលពីថ្ងៃទី២៩-៨-២០០៩ វេលាម៉ោង ៥ និង ៣០នាទី ពេលប្តីខ្លួនបើករថយន្តកាមរីស៊េរី ១៩៩៤ ពាក់ផ្លាកលេខ: 2E ០៩៩៤ ភ្នំពេញ ចេញពីតូបលក់ដូរ កាត់តូបជនជាប់ចោទ ហើយជនជាប់ចោទបានធ្វើឲ្យឆ្កតថ្នាំឡានខាងក្រោយ។ លុះព្រឹកឡើងនៅថ្ងៃទី២០-៨-២០០៩ ពេលខ្លួន និងប្តីទៅសួរនាំឲ្យឈ្មោះ [redacted] ជួយចេញ ១០ ដុល្លាអាមេរិក ស្រាប់តែឈ្មោះនេះ ជេរប្រមាថខ្លួន រួចចាប់មួលដៃខ្លួនបណ្តាលឲ្យផ្លោះគ្រិច ហើយខ្លួនបានព្យាបាលអស់ប្រាក់ ៣០០ ដុល្លាអាមេរិក។ ការអះអាងនេះមានសាក្សីជាច្រើនបញ្ជាក់ទៀតផង។

៣.តាមការអះអាងរបស់ជនជាប់ចោទនៅតុលាការថ្នាក់ក្រោមថា: ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តាមពិតឈ្មោះ [redacted] ដែលត្រូវជាប្តីរបស់ឈ្មោះ [redacted] ប្រពន្ធ ហើយបានបើកឡានចូលក្នុងផ្សារ ចង់កិនរបស់របរលក់ដូររបស់ខ្លួន ហើយបានជេរខ្លួនទៀត។ លុះដល់ថ្ងៃទី២០-៨-២០០៩ ស្រាប់



Scanned by CamScanner

តែពីនាក់ប្ដីប្រពន្ធបានមកទាលុយខ្លួន ១០ដុល្លារអាមេរិក ដើម្បីជួសជុលឡាន តែខ្លួនថា អត់មាន ស្រាប់តែប្ដីឈ្មោះ [redacted] មកពីលើឡាន យកខ្លួន ហើយដាល់ខ្លួនពីរបីដៃ ធ្វើឲ្យខ្លួនវង្វេងស្មារតី។ ប៉ុន្តែការអះអាងនេះពុំមានអ្វីជាកស្តុតាងយកមកបញ្ជាក់ឡើយ។

៤.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទៈ **បង្ករបួសស្នាមដោយចេតនា និងជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២០-៨-២០០៩ តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៣០៧ និង ១០៧ នៃក្រមព្រហ្មទណ្ឌ។

៥.រឿងក្ដីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេត និងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះសាលាឧទ្ធរណ៍មិនចាំបាច់លើក យកសំអាងហេតុនេះមកបញ្ជាក់ ថ្មីទៀតទេ។

៦.សាលក្រមព្រហ្មទណ្ឌលេខៈ ០៩ "ន" ចុះថ្ងៃទី២១-០១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយគប្បីតម្កល់ទុកជាបានការតទៅ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១.ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-០១-២០១១ របស់ឈ្មោះ [redacted] ជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ០៩ "ន" ចុះថ្ងៃទី២១-០១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះប្រកាសជាសាធារណៈថ្ងៃទី០៧-៣-២០១២ ចំពោះមុខដើមបណ្ដឹង កំបាំងមុខជនជាប់ចោទ ទុកសិទ្ធិឲ្យប្ដឹងតវ៉ាតាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** ហត្ថលេខា [redacted]

**ចៅក្រមប្រឹក្សា** ហត្ថលេខា [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** ហត្ថលេខា [redacted]

---

...តាមច្បាប់ដើម-
ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]